ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកំពង់ស្ពឺ
សំណុំរឿងរដ្ឋប្បវេណីលេខ: ២៧៣
ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២២
សាលក្រមលេខ: ១២ (ឌ)
ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ស្ពឺ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣

ដោយមានសមាសភាពដូចតទៅ

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ស្ពឺ

**ក្រឡាបញ្ជី**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ស្ពឺ

បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់លើសំណុំរឿងរដ្ឋប្បវេណីលេខ: ២៧៣ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៣ ដែលមាន៖

<u>ដើមចោទឈ្មោះ</u> [redacted] ចន្ទិសាឮ ភេទស្រី អាយុ៣០ឆ្នាំ មុខរបរ ធ្វើការធនាគារ មានទីលំនៅភូមិ [redacted]។

ដោយមានលោក [redacted] ជាអ្នកតំណាងដោយអាណត្តិ មានអត្តលេខ ២៤៧២T ជាមេធាវីនៃក្រុមមេធាវី [redacted]។

<u>ចុងចម្លើយឈ្មោះ</u> [redacted] វត្តនា ភេទប្រុស អាយុ២៨ឆ្នាំ មុខរបរ យោធា មានទីលំនៅ [redacted]។

## <u>អង្គហេតុ និងចំណុចវិវាទ</u>

**១./ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ**

១./ លែងលះពីប្តីឈ្មោះ [redacted] វត្តនា ភេទប្រុស អាយុ២៨ឆ្នាំ។

២./ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

**២./ អង្គហេតុនៃការទាមទារ**

នាងខ្ញុំបានរៀបការជាមួយឈ្មោះ [redacted] វត្តនា តាំងពីឆ្នាំ២០១៩មកម្លេះ ដោយពួកយើងបានចុះសំបុត្រអាពាហ៍ពិពាហ៍ នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ដោយការរៀបការនេះពួកខ្លួនបានរស់នៅជាមួយគ្នារយៈ



Scanned with CamScanner

ពេល៤ឆ្នាំទៅហើយ ប៉ុន្តែក្រោយពេលពួកយើងរៀបការមកគាត់ចេះតែមានស្រីថ្មីចោលរូបខ្ញុំជាប្រពន្ធ ដោយមិនឱ្យខ្ញុំមានក្តីសុខនោះទេ ទើបនៅពេលនេះខ្ញុំទ្រាំមិនបាន និងទង្វើរបស់គាត់ទៀតលែងបានទើប សម្រេចចិត្តដាក់ពាក្យបណ្តឹងមកតុលាការតែម្តង។

## ៣./ ការសាកល្បងផ្សះផ្សា

តុលាការបានធ្វើការសាកល្បងផ្សះផ្សាភាគីដើមចោទ និងភាគីចុងចម្លើយ នៅគ្រប់នីតិវិធីរបស់តុលាការដែលមាននីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែភាគីទាំងសងខាងមិនមានឆន្ទៈក្នុងការរួមរស់នៅជាមួយគ្នាវិញនោះទេ។

## ៤./ ការអះអាងរបស់គូភាគី

<u>ការអះអាងរបស់ដើមចោទ</u>

នាងខ្ញុំបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ [redacted] វត្ថា តាំងពីឆ្នាំ២០១៩ ដោយពួកយើងបានចុះសំបុត្រអាពាហ៍ពិពាហ៍នៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ដោយការរៀបការនេះពួកខ្លួនបានរស់នៅជាមួយគ្នារយៈពេល៤ឆ្នាំមកហើយ។ ប៉ុន្តែក្រោយពួកយើងរៀបការមកគាត់ចេះតែមានស្រីចោលរូបខ្លួនជាប្រពន្ធ ដោយមិនឱ្យខ្ញុំមានក្តីសុខនោះទេ ទើបពេលនេះនាងខ្ញុំទ្រាំ និងទង្វើប្តីនាងខ្ញុំលែងបានទៀតហើយក៏សម្រេចចិត្តដាក់ពាក្យបណ្តឹងលែងលះមកតុលាការតែម្តង និងសុំឱ្យតុលាការមេត្តាសម្រេចអំពីការសុំលែងលះរបស់នាងខ្ញុំដោយក្តីអនុគ្រោះ។ ក្រោយពេលដែលពួកខ្លួនរៀបការរួចមិនមានទ្រព្យសម្បត្តិរួម និងមិនមានកូនជាមួយគ្នានោះទេ ដូច្នេះ នាងខ្ញុំនៅពេលនេះស្នើសុំមកតុលាការ សម្រេចតែអំពីការលែងលះ តែប៉ុណ្ណោះ។ នៅពេលនេះខ្លួនសូមទាមទារលែងលះពីចុងចម្លើយ ចំពោះប្រាប់ប្រដាប់ក្តីខ្លួនជាអ្នកទទួលបន្ទុកទាំងស្រុង។

<u>ការអះអាងរបស់ចុងចម្លើយ</u>

ខ្លួនសូមធ្វើការអះអាងថា ខ្លួនពិតជាបានរៀបការជាមួយប្រពន្ធឈ្មោះ [redacted] ចន្ទិសារ្យ ពិតមែន ដោយក្រោយពេលរៀបការពួកខ្លួនទាំងពីរនាក់បានទៅចុះសំបុត្រអាពាហ៍ពាពិពាហ៍ ត្រឹមត្រូវតាមផ្លូវច្បាប់ ដោយមានសំបុត្រអាពាហ៍ពិពាហ៍លេខ ១៥ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩។ ក្នុងអំឡុងពេលដែលពួកខ្លួនរស់នៅជាមួយគ្នា ពួកខ្លួនទាំងពីរនាក់មិនមានទ្រព្យសម្បត្តិរួម ឬ បំណុលរួមនោះទេ ហើយក៏មិនទាន់មានកូនរួមគ្នាផងដែរ។

ចំពោះការទាមទាររបស់ភាគីដើមចោទដែលស្នើសុំលែងលះពីខ្លួន ត្រង់ចំណុចនេះខ្លួនយល់ព្រមលែងលះពីភាគីដើមចោទចាប់ពីពេលនេះតទៅ។ ត្រង់ចំណុចដែលភាគីដើមចោទជាអ្នកទទួលរ៉ាប់រងបន្ទុកប្រាប់ប្រដាប់ក្តីទាំងស្រុង ត្រង់ចំណុចនេះខ្លួនយល់ព្រមតាមការស្នើសុំរបស់ភាគីដើមចោទ។

## ៥./ ចំណុចវិវាទ

-តើការទាមទាររបស់ដើមចោទមានមូលហេតុលែងលះត្រឹមត្រូវតាមផ្លូវច្បាប់ដែរ ឬ ទេ?

## ៦./ វត្ថុតាងដែលដាក់ដោយភាគីដើមចោទ

សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំត្រពាំងគង។



Scanned with CamScanner

## សំអាងហេតុ

### ការវិនិច្ឆ័យអំពីការលែងលះ

នៅក្នុងរឿងនេះតាមការអះអាងរបស់ភាគីដើមចោទ និងភាគីចុងចម្លើយបានលើកឡើងថា ភាគីទាំងសងខាងមិនមានឆន្ទៈក្នុងការបន្តចំណងអាពាហ៍ពិពាហ៍និងគ្នាតទៅទៀតបាន ដែលទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ដើមចោទ និងចុងចម្លើយត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថានឹងអាចបង្វិលទៅរកភាពដើមវិញនោះទេ គប្បីតុលាការពិនិត្យ និងសម្រេចតាមច្បាប់។

### បន្ទុកនៃប្រាក់ប្រដាប់ក្តី

ដើមចោទស្នើសុំទទួលបន្ទុកលើប្រាក់ប្រដាប់ក្តីផ្សេងៗដោយខ្លួនឯង ដូច្នេះ គប្បីតុលាការសម្រេចឱ្យដើមចោទទទួលបន្ទុកប្រាក់ប្រដាប់ក្តីផ្សេងៗតាមការស្នើសុំ ដោយអនុលោមតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ហេតុដូច្នេះ សម្រេច

១./ ឱ្យដើមចោទឈ្មោះ [redacted] ចន្ទិសារ្យ លែងលះពីចុងចម្លើយឈ្មោះ [redacted] វត្តនា និងឱ្យដើមចោទស្ថិតនៅក្នុងភាពមេម៉ាយក្នុងរយៈពេល ១២០ថ្ងៃ គិតចាប់ពីថ្ងៃនេះតទៅ។

២./ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះបានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣ នៅចំពោះមុខដើមចោទ និងចុងចម្លើយ។

ទុកសិទ្ធិឱ្យគូភាគីក្នុងការប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

**ក្រឡាបញ្ជី** | **ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted] | ហត្ថលេខា និងត្រា [redacted]

---

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃអង្គារ ០២រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

កំពង់ស្ពឺ, ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner